Cambodian Human Rights Committee

# Statement of the Cambodian Human Rights Committee

*"Thailand's Aggression Against Cambodia: Cambodia's Sovereignty and Human Rights Under Threat"*

The Cambodian Human Rights Committee (CHRC) expresses grave concern and strong condemnation on the recent acts of aggression and serious human rights violations committed by the Kingdom of Thailand against the Kingdom of Cambodia. These unlawful and hostile actions have severely undermined Cambodia's sovereignty, territorial integrity, and fundamental rights of the Cambodian people, and constitute a blatant breach of international and regional laws, and universally accepted human rights standards.

Thailand's aggression against Cambodia has caused the loss of Cambodian civilian lives and injuries, which violates the right to life. Furthermore, the attacks have forced thousands of Cambodian civilians residing along border areas to be displaced while their homes and livelihoods were destroyed, violating their rights to economy and adequate housing.

The conducted airstrikes using F-16 fighter jet and heavy weapons by Thailand, targeting and destroying parts of the sacred Preah Vihear Temple, a UNESCO World Heritage site, and Cambodian pagodas, constitute both a cultural and religious violation, infringing the 1954 Hague Convention for the Protection of Cultural Property in the Event of Armed Conflict, as well as UNESCO regulations and the World Heritage Convention, Article 27 of the Universal Declaration of Human Rights (UDHR), Article 27 of the International Covenant on Civil and Political Rights (ICCPR), and Article 15 of the International Covenant on Economic, Social and Cultural Rights (ICESCR).

Thailand has engaged in acts of racial discrimination against Cambodian migrant workers residing and working in Thailand, including physical assaults, threats, and other forms of violence, which violate Article 2 and 5 of the International Convention on the Elimination of All Forms of Racial Discrimination (ICERD), to which Thailand is a State Party, and the ASEAN Human Rights Declaration (Article 4), which guarantees freedom from discrimination. These acts create a climate of fear and violate the right to life and security under the Universal Declaration of Human Rights (Article 3). **Samdech Moha Borvor Thipadei Hun Manet**, Prime Minister of the Kingdom of Cambodia, has called for Cambodian citizens to uphold morality, dignity, and discipline, and to refrain from any acts of discrimination or actions that may affect the Thai Embassy in Cambodia, Thai companies, or Thai nationals residing in the Kingdom of Cambodia.

Cambodia remains firmly committed to resolving all disputes through peaceful and diplomatic means. Cambodia believes that dialogue, mutual respect, and adherence to international law are the most effective tools for maintaining stability and fostering long-term cooperation.

CHRC urges the Government of Thailand to immediately cease all actions that infringe upon Cambodia's sovereignty and to adhere strictly to its obligations under international and regional laws. CHRC calls for the matter to be addressed through peaceful dialogue and appropriate diplomatic and legal mechanisms, in accordance with the rule of law and mutual respect.

Phnom Penh, Friday 25 July, 2025

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

*"ការឈ្លានពានរបស់ថៃមកលើកម្ពុជា៖ អធិបតេយ្យភាព និងស្ថានភាពសិទ្ធិមនុស្សរបស់កម្ពុជា វងការគំរាមកំហែង"*

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សម្តែងការព្រួយបារម្ភ និងថ្កោលទោសយ៉ាងខ្លាំងចំពោះសកម្មភាពឈ្លានពាន និងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលប្រព្រឹត្តឡើងដោយព្រះរាជាណាចក្រថៃ មកលើព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពខុសច្បាប់ និងជាអរិភាពទាំងនេះ បានប៉ះពាល់ដល់អធិបតេយ្យភាព បូរណភាពទឹកដី និងសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា ហើយក៏ជាការបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់អន្តរជាតិនិងតំបន់ ព្រមទាំងបទដ្ឋានសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាសកល។

ការឈ្លានពានរបស់ប្រទេសថៃមកលើកម្ពុជា បានបណ្តាលឱ្យជនស៊ីវិលកម្ពុជាបាត់បង់ជីវិត និងរងរបួស ដែលជាការរំលោភសិទ្ធិរស់រានមានជីវិត។ លើសពីនេះ ការវាយប្រហារបានបង្ខំឱ្យជនស៊ីវិលកម្ពុជារាប់ពាន់នាក់ ដែលរស់នៅតាមតំបន់ព្រំដែនត្រូវជម្លៀសខ្លួនចេញ ខណៈដែលផ្ទះសម្បែង និងជីវភាពរស់នៅរបស់ពួកគេត្រូវបានបំផ្លាញ ដែល ជាការរំលោភលើសិទ្ធិសេដ្ឋកិច្ច និងសិទ្ធិមានលំនៅដ្ឋានសមរម្យ។

ការវាយប្រហារតាមអាកាសដោយប្រើប្រាស់យន្តហោះចម្បាំង F-16 និងអាវុធធុនធ្ងន់របស់ប្រទេសថៃ ដោយបានកំណត់គោលដៅ និងបំផ្លាញផ្នែកខ្លះនៃប្រាសាទព្រះវិហារដ៏ពិសិដ្ឋ ដែលជាតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ(UNESCO) និងវត្តមួយចំនួនរបស់កម្ពុជា គឺជាការរំលោភលើវិស័យវប្បធម៌ និងសាសនា បំពានលើអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងឧបទ្ទវហេតុជម្លោះប្រដាប់អាវុធ ព្រមទាំងរំលោភលើបទប្បញ្ញត្តិនានារបស់អង្គការយូណេស្កូ អនុសញ្ញាបេតិកភណ្ឌពិភពលោក មាត្រា២៧ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) មាត្រា២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) និងមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR)។

ប្រទេសថៃបានធ្វើសកម្មភាពរើសអើងពូជសាសន៍លើពលករចំណាកស្រុកខ្មែរដែលរស់នៅ និងធ្វើការក្នុងប្រទេសថៃ ដោយការវាយដំលើរាងកាយរហូតមានដល់បាត់បង់ជីវិត ការគំរាមកំហែង និងអំពើហិង្សាក្នុងទម្រង់ផ្សេងៗទៀត ដែលបំពានលើមាត្រា២ និង ៥ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់

រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) ដែលប្រទេសថៃជារដ្ឋភាគី និងសេចក្តីប្រកាស សិទ្ធិមនុស្សអាស៊ាន (AHRD) មាត្រា៤ ដែលធានាសេរីភាពពីការរើសអើង។ ទង្វើទាំងនេះ បង្កើតបរិយាកាសនៃការភ័យខ្លាច និងរំលោភលើសិទ្ធិរស់រានមានជីវិត និងសន្តិសុខក្រោមសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា៣)។ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអំពាវនាវដល់ប្រជាពលរដ្ឋកម្ពុជា ប្រកាន់ខ្ជាប់នូវសីលធម៌ សេចក្តីថ្លៃថ្នូរ វិន័យ និងចៀសវាងការរើសអើង ឬសកម្មភាពណាមួយដែលអាចប៉ះពាល់ដល់ស្ថានទូតថៃប្រចាំនៅកម្ពុជា ក្រុមហ៊ុនថៃ ឬជនជាតិថៃ ដែលកំពុងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

កម្ពុជានៅតែប្តេជ្ញាយ៉ាងមុតមាំក្នុងការដោះស្រាយវិវាទទាំងអស់ដោយសន្តិវិធី និងការទូត។ កម្ពុជាជឿជាក់ថា ការសន្ទនា ការគោរពគ្នាទៅវិញទៅមក និងការប្រកាន់ខ្ជាប់នូវច្បាប់អន្តរជាតិ ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតសម្រាប់រក្សាស្ថិរភាព និងជំរុញកិច្ចសហប្រតិបត្តិការរយៈពេលវែង។

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា សូមជំរុញដល់រាជរដ្ឋាភិបាលថៃឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់សកម្មភាពដែលរំលោភលើអធិបតេយ្យភាពរបស់កម្ពុជា ហើយត្រូវប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹងចំពោះកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ និងតំបន់។ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា អំពាវនាវឱ្យមានការដោះស្រាយបញ្ហានេះតាមរយៈការសន្ទនាដោយសន្តិវិធី យន្តការការទូត និងច្បាប់សមស្រប ស្របតាមគោលការណ៍នីតិរដ្ឋ និងការគោរពគ្នាទៅវិញទៅមក៕

ថ្ងៃសុក្រ ១៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥